សួស្តី នៅក្នុងរូបភាពនេះ គឺយើងនឹងនិយាយអំពីពិធីបុណ្យចូលឆ្នាំខ្មែរ បាទ អញ្ចឹងតើពិធីបុណ្យចូលឆ្នាំខ្មែរនៅក្នុងប្រទេសកម្ពុជា គេប្រព្រឹត្តទៅបែបណាខ្លះ ? យើងមកមើលរូបភាពទាំងអស់គ្នាតែម្តង។

នៅក្នុងរូបភាពទី ១ គឺជារូបភាពរបស់ព្រះវិហារមួយ អញ្ចឹងជាទូទៅនៅក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ ប្រជាជនកម្ពុជា គាត់តែងតែទៅវត្ត បាទ ហើយនៅក្នុងវត្តគឺមានច្រើន មានដូចជាព្រះវិហារ មានដូចជាសាលាឆាន់ មានដូចជាចេតិយ ហើយនៅក្នុងរូបភាពនេះ យើងឃើញថា មានគ្រួសារមួយគ្រួសារ ដែលមានមនុស្សបីនាក់នៅក្នុងរូបភាព ដែលយើងឃើញមានមនុស្សពណ៌ខ្មៅ បាទ មនុស្សពណ៌ខ្មៅ ដែលក្នុងនោះយើងឃើញមានកូនក្មេងតូចមួយនិងមនុស្សធំពីរនាក់ បាទ មនុស្សធំពីរនាក់និងកូនក្មេងតូចមួយ ពួកគាត់ទាំងអស់គ្នានោះកំពុងតែដើរទៅកាន់ព្រះវិហារមួយ។ អញ្ចឹងគាត់បានដើរទៅកាន់ព្រះវិហារ ដែលព្រះវិហារនោះ គឺជាព្រះវិហារដែលនៅក្នុងវត្ត។ អញ្ចឹងវត្តដែលនៅក្នុងព្រះពុទ្ធសាសនា គឺតែងតែមានព្រះវិហារ មានសាលាឆាន់ បាទ សាលាឆាន់ គឺគេប្រើសម្រាប់ព្រះសង្ឃ ឬក៏លោកសង្ឃ គាត់ សម្រាប់ឆាន់ចង្ហាន់ បាទ អញ្ចឹងព្រះសង្ឃ ឬក៏លោកសង្ឃ គាត់ឆាន់ចង្ហាន់នៅក្នុងសាលាឆាន់ នៅពេលដែលប្រជាជន ឬក៏នៅពេលដែលប្រសក [បាសក/ឧបាសក] គាត់យកចង្ហាន់ទៅប្រគេនព្រះសង្ឃ បាទ ចំណែកព្រះវិហារ ព្រះវិហារគឺគេប្រើប្រាស់សាងសង់ឡើង សម្រាប់តម្កល់ព្រះពុទ្ធបដិមា អញ្ចឹងគេយករូបព្រះពុទ្ធ បាទ រូបព្រះពុទ្ធ ដែលឬជារូបចម្លាក់ថ្ម ឬក៏រូបចម្លាក់ស៊ីម៉ងត៍ នៅពេលដែលគេឆ្លាក់ជាព្រះពុទ្ធហើយ គេហៅថាព្រះពុទ្ធបដិមា អញ្ចឹងគេយករូបព្រះពុទ្ធបដិមាទៅដាក់ក្នុងព្រះវិហារ ហើយគេចូលព្រះវិហារដើម្បីថ្វាយបង្គំព្រះ។ អញ្ចឹងជាទូទៅប្រជាជនយើងតែងតែទៅវត្ត ហើយចូលព្រះវិហារដើម្បីថ្វាយបង្គំព្រះ ម្យ៉ាងវិញទៀត នៅពេលដែលព្រះសង្ឃគាត់សូត្រធម៌ ព្រះសង្ឃដែល ដល់ម៉ោងសូត្រធម៌ពេលព្រឹកឡើង តែងតែចូលទៅសូត្រធម៌នៅក្នុងព្រះវិហារ នៅ គាត់សូត្រធម៌នៅចំពោះមុខព្រះពុទ្ធបដិមានោះផងដែរ។ អញ្ចឹងរូបភាពនេះ យើងឃើញថាព្រះវិហារមួយ ដែលមានកម្ពស់ខ្ពស់ផុតពីដី អញ្ចឹងព្រះវិហារមានកម្ពស់ខ្ពស់ផុតពីដី ដែលនៅខាងក្រោមព្រះវិហារគឺមានសសរជាច្រើន អញ្ចឹងព្រះវិហារអាចខ្ពស់បាន គឺដោយសារមានសសរ សសរទ្រព្រះវិហារ ហើយយើងអាចឡើងទៅកាន់ព្រះវិហារនោះបាន តាមរយៈជណ្តើរ បាទ អញ្ចឹងយើងឡើងទៅកាន់ព្រះវិហារតាមរយៈជណ្តើរ ព្រះវិហារនោះគឺមានបង្អួចជាច្រើន បាទ មានបង្អួចជាច្រើន ដែលនៅខាងៗនៃជញ្ជាំង អញ្ចឹងជញ្ជាំងព្រះវិហារ គឺមានបង្អួចជាច្រើន។ ចំណែកដំបូលព្រះវិហារគឺមានពណ៌ទឹកក្រូច បាទ ដំបូលព្រះវិហារគឺមានពណ៌ទឹកក្រូច ហើយមានពីរជាន់ អញ្ចឹងដំបូលនោះគឺមានពីរជាន់ នៅលើដំបូលគឺគេប្រើប្រាស់រចនាបថខ្មែរ បាទ រចនាបថ យើងហៅថារចនាបថ ឬក៏ក្បូរក្បាច់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលយើងឃើញមានកន្ទុយនាគ បាទ រូបកន្ទុយនាគ ឬក៏ក្បាច់កន្ទុយនាគ នៅលើចុងដំបូលនីមួយៗផងដែរ។ អញ្ចឹងនៅក្នុងរូបភាពនេះ គឺយើងនិយាយអំពីថ្ងៃចូលឆ្នាំខ្មែរ មានគ្រួសារមួយគ្រួសារហ្នឹង គាត់បានយកចង្ហាន់ទៅប្រគេនលោក នៅក្នុងព្រះវិហារ នៅក្នុងវត្តព្រះពុទ្ធសាសនា។

ចូលដល់រូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញមានមនុស្សបីនាក់ បាទ មនុស្សបីនាក់ ដែលជាគ្រួសារតែមួយ បាទ មនុស្សបីនាក់ ដែលជាគ្រួសារតែមួយ ដែលនៅខាងមុខគេ គឺជាបុរសម្នាក់ ដែលគាត់មានអាយុប្រហែលជា ៤០ ឆ្នាំ បាទ គាត់មានអាយុប្រហែលជា ៤០ ឆ្នាំ គាត់ពាក់អាវក្រណាត់ សាច់ក្រណាត់ ដៃខ្លី អាវគាត់ពណ៌ស្វាយ គាត់ស្លៀកខោជើងវែង ប៉ុន្តែមិនមានពាក់ស្បែកជើងនោះទេ បាទ ហើយគាត់ស្លៀកខោជើងវែងពណ៌ស នៅនឹងដៃរបស់គាត់ គឺកាន់ស្លាដក់មួយ នៅនឹងដៃកាន់ស្លាដក់ ស្លាដក់គឺជាថាសមួយដែលគេដាក់នូវចង្ហាន់ ក៏ដូចជាវត្ថុផ្សេងៗសម្រាប់ប្រគេនព្រះសង្ឃ ដែលនៅក្នុងនោះមានដូចជាស្លរស មានដូចជាតែ មានដូចជាធូប និងមានដូចជាទៀនជាដើម។ អញ្ចឹងគេរៀបចំវត្ថុទាំងអស់នោះដាក់នៅលើថាស បន្ទាប់មកគេខ្ទប់ដោយថង់មួយ គេខ្ទប់ដោយថង់មួយ ដែលយើងហៅថាស្លាដក់។ នៅខាងក្រោយបុរសម្នាក់នោះគឺមាននារីម្នាក់ បាទ គាត់អាយុប្រហែលជាខ្ទង់ ៤០ ឆ្នាំដូចគ្នា គាត់ប្រហែលជាប្រពន្ធរបស់បុរសម្នាក់នោះ បាទ នារីម្នាក់នោះ គាត់ពាក់អាវប៉ាក់ គាត់ពាក់អាវប៉ាក់ពណ៌ស និងស្លៀកសំពត់ហូលឬក៏ផាមួងពណ៌ប្រផេះ ដើរដោយមិនមានពាក់ស្បែកជើងនោះទេ។ អញ្ចឹងជាទូទៅនៅក្នុងប្រទេសកម្ពុជា នៅពេលដែលចូលឆ្នាំខ្មែរ គេតែងតែទៅវត្ត ហើយទៅវត្ត នារីដែល នៅក្នុងប្រជាជនកម្ពុជាដែលជានារី គឺគាត់តែងតែស្លៀកពាក់ខោអាវប្រពៃណី ឬក៏សម្លៀកបំពាក់ប្រពៃណី ដែលសម្លៀកបំពាក់ទាំងនោះមានដូចជាអាវប៉ាក់ ហូល ផាមួងជាដើម អញ្ចឹងនារីម្នាក់នេះ គាត់ពាក់អាវប៉ាក់និងហូលឬក៏ផាមួង ដើរនៅក្រោយប្ដីរបស់គាត់។ ចំណែកនៅខាងក្រោយនារីម្នាក់នោះគឺមានក្មេងប្រុសម្នាក់ បាទ ក្មេងប្រុសម្នាក់នោះ គឺជាកូនរបស់អ្នកទាំងពីរដែលនៅខាងមុខ។ អញ្ចឹងក្មេងប្រុសម្នាក់នោះ ដើរតាមខាងក្រោយនារីម្នាក់នោះ គឺក្មេងប្រុសម្នាក់នោះ គាត់ពាក់អាវដៃខ្លីពណ៌ស និងស្លៀកខោជើងខ្លីពណ៌សដែរ។ អញ្ចឹងគាត់ដើរមកវត្តជាមួយនឹងគ្រួសាររបស់គាត់ គាត់ដើរមកវត្តជាមួយនឹងឪពុកម្ដាយរបស់គាត់ បាទ ជាទូទៅ នៅពេលដែលយើងដើរចូលវត្ត យើងមិនត្រូវពាក់មួកនោះទេ យើងត្រូវដោះមួកចេញ ព្រោះជាសុជីវធម៌ អញ្ចឹងដើម្បីរក្សាសុជីវធម៌ ព្រោះនៅប្រទេសកម្ពុជាយើងប្រកាន់នូវសុជីវធម៌ជាធំ ដូច្នេះនៅពេលដែលយើងចូលវត្ត យើងមិនត្រូវពាក់មួកនោះទេ។ ហើយមួយវិញទៀត នៅពេលដែលយើងចូលព្រះវិហារ យើងត្រូវដោះស្បែកជើង បាទ ព្រោះព្រះវិហារគឺជាកន្លែងដាក់ព្រះពុទ្ធបដិមា

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងយើងមិនអាចពាក់ស្បែកជើងចូលនោះទេ យើងត្រូវតែគោរព។ ជាក់ស្ដែងដូចជានៅក្នុងរូបភាពទី ២ នេះ គឺមនុស្សទាំងបីនាក់ គាត់កំពុងតែដើរទៅកាន់ព្រះវិហារ ដូច្នេះយើងមិនមានឃើញគាត់ពាក់មួក ឬក៏ពាក់ស្បែកជើងនោះទេ ព្រោះគាត់ត្រូវរក្សាសុជីវធម៌ និងគោរពទៅដល់ព្រះពុទ្ធបដិមា ដែលនៅក្នុងព្រះវិហារ។

នៅក្នុងរូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា បុរសម្នាក់នោះជាមួយនឹងប្រពន្ធគាត់ ក៏ដូចជាកូនស្រីរបស់គាត់ បានចូលមកដល់ក្នុងព្រះវិហាររួចហើយ បាទ ចូលដល់ក្នុងព្រះវិហារ បន្ទាប់មកយើងឃើញថាពួកគេទាំងអស់គ្នាបានលុតជង្គង់ចុះ ហើយគាត់ដាក់ស្លាដក់ បាទ ដែលគាត់កាន់អម្បាញ់មិញ គាត់ដាក់ស្លាដក់ចុះនៅខាងមុខគាត់ ហើយគាត់លុតជង្គង់ ថ្វាយបង្គំ គាត់លើកដៃទាំងពីរឡើង លើកដៃទាំងពីរឡើងដើម្បីសំពះ បាទ សំពះ គាត់ដាក់ដៃរបស់គាត់ ត្រឹមច្រមុះរបស់គាត់ អញ្ចឹងគាត់ដាក់ដៃត្រឹមច្រមុះ ហើយលើកដៃសំពះឡើង ដើម្បីថ្វាយបង្គំព្រះសង្ឃ ដែលនៅខាងមុខ។ យើងឃើញនៅក្នុងរូបភាពនេះ គឺមានព្រះសង្ឃមួយកំពុងតែអង្គុយពែនភ្នែននៅខាងមុខបុរសម្នាក់នោះ បាទ ដែលព្រះសង្ឃគឺអង្គុយនៅទីតាំងដែលខ្ពស់ជាងបុរសម្នាក់នោះ អញ្ចឹងព្រះសង្ឃ គឺជាបុគ្គលដែលគេត្រូវគោរព ដូច្នេះព្រះសង្ឃត្រូវអង្គុយខ្ពស់ជាងមនុស្សធម្មតា។ បាទ ព្រះសង្ឃ គឺគាត់ពុំមានស្លៀកពាក់ដូចយើងធម្មតា ប្រជាជនធម្មតានោះទេ គឺព្រះសង្ឃគាត់គ្រងស្បង់ចីពរ បាទ គាត់គ្រងស្បង់ចីពរពណ៌លឿង ហើយព្រះសង្ឃត្រូវកោរសក់ គាត់មិនមានសក់នោះទេ ព្រោះជាវិន័យរបស់ព្រះសង្ឃ គឺត្រូវតែកោរសក់ចេញឲ្យអស់។

នៅក្នុងរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញមានក្អម ក្អមឬក៏ឆ្នាំងដី ដែលគេដាក់ខ្សាច់ និងមានដោតធូបនៅទីនោះ។ អញ្ចឹងនៅក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ បន្ទាប់ពីយើងប្រគេនចង្ហាន់ទៅដល់ព្រះសង្ឃ ប្រគេនស្លាដក់ទៅដល់ព្រះសង្ឃរួចហើយ យើងត្រូវចេញមកខាងក្រៅព្រះវិហារ ដើម្បីពូនភ្នំខ្សាច់។ អញ្ចឹងនៅក្នុងរូបភាពនេះ គឺយើងនិយាយអំពីការពូនភ្នំខ្សាច់ អញ្ចឹងពូនភ្នំខ្សាច់គឺយើងយកខ្សាច់ឬក៏កើបខ្សាច់មក ហើយយកច្បាមខ្សាច់នោះ ដាក់នៅក្នុងបាតដៃរបស់យើង រួចហើយបោះទៅលើភ្នំខ្សាច់មួយ ដែលគេមានរៀបចំជាពំនូកខ្សាច់ យើងបោះខ្សាច់នោះ ឬក៏យើងចាប់ច្បាមខ្សាច់នោះដាក់នៅក្នុងដៃ បន្ទាប់មកដាក់ទៅលើពំនូកខ្សាច់នោះ ហើយយើងអុជធូប បន្ទាប់មកយើងបួងសួង យើងបួងសួងពូនភ្នំខ្សាច់នេះ គឺដើម្បីសុំសេចក្ដីសុខ ជាមួយនឹង កុំឲ្យមានគ្រោះអាក្រក់កើតឡើង គឺយើងសុំសេចក្ដីសុខនៅក្នុងថ្ងៃចូលឆ្នាំថ្មី គឺដើម្បីតំណាងថាផ្ដាច់កម្មពៀរពីឆ្នាំចាស់។ អញ្ចឹងដើម្បីឲ្យមានសេចក្ដីសុខ ប្រជាជនកម្ពុជាតែងតែធ្វើការពូនភ្នំខ្សាច់ នៅពេលដែលចូល នៅពេលដែល ក្នុងថ្ងៃចូលឆ្នាំថ្មី។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ចូលដល់រូបភាពទី ៥ នៅក្នុងរូបភាពទី ៥ បន្ទាប់ពីគ្រួសារនោះគាត់បានទៅដល់ព្រះវិហាររួចហើយ គាត់បានប្រគេនស្លាដក់ទៅដល់ព្រះសង្ឃ ក៏ដូចជាពូនភ្នំខ្សាច់រួចហើយ ពួកគាត់ទាំងអស់គ្នា ក៏បានដើរចេញមកខាងក្រៅវិញ។ អញ្ចឹងបន្ទាប់ពីយើងប្រគេនស្លាដក់ ឬក៏ប្រគេនចង្ហាន់ទៅដល់ព្រះសង្ឃ ព្រះសង្ឃនឹងសូត្រធម៌ ឬក៏ឲ្យពរ ដើម្បីឲ្យយើងបានជួបនូវសេចក្តីសុខ បន្ទាប់មកយើងក៏ឧទ្ទិស បាទ ឧទ្ទិសទៅដល់ដូនតា ឬក៏ជីដូនជីតារបស់យើងដែលបានស្លាប់។ អញ្ចឹងឧទ្ទិស យើងមានន័យថា ការផ្សង ឬក៏ប៉ង ឬក៏ជូនផល អញ្ចឹងគាត់ជូនផលទៅដល់ជីដូនជីតារបស់គាត់រួចរាល់ហើយ បន្ទាប់មកពួកគាត់ទាំងអស់ ក៏បានចុះពីព្រះវិហារវិញ។ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថា ពួកគាត់បានចេញពីព្រះវិហារមក ដោយចុះតាមកាំជណ្តើរ អញ្ចឹងគាត់ចុះតាមកាំជណ្តើរ ចេញមកខាងក្រៅ ដោយបុរសម្នាក់នោះជាអ្នកចុះមុន ជាអ្នកដើរនៅខាងមុខ បន្ទាប់មកគឺនារីដែលជាប្រពន្ធ គាត់ដើរនៅកណ្តាល ហើយកូនប្រុសរបស់ពួកគាត់ គឺដើរនៅខាងក្រោយគេ។ អញ្ចឹងពួកគាត់ត្រលប់ចេញពីព្រះវិហារដែលនៅក្នុងវត្តនោះ ហើយពួកគាត់ត្រលប់ទៅផ្ទះវិញ។

នៅក្នុងរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ បន្ទាប់ពីគាត់ចេញពីក្នុងវត្តរួចហើយ អ្នកទាំងបីក៏បានជិះម៉ូតូ អញ្ចឹងគាត់ជិះម៉ូតូត្រលប់ទៅផ្ទះវិញ យើងឃើញថានៅក្នុងនេះម៉ូតូគាត់គឺមានពណ៌ផ្កាឈូក បាទ លាយស ដែលគាត់ដាក់កញ្ចក់សម្រាប់មើលក្រោយផងដែរ អញ្ចឹងម៉ូតូយើង នៅពេលដែលយើងដាក់កញ្ចក់សម្រាប់មើលក្រោយ គឺធ្វើឲ្យយើងមានសុវត្ថិភាព ព្រោះថាយើងពុំចាំបាច់រំខាន ឬក៏យើងពុំចាំបាច់ងាកក្រោយនោះទេ ដើម្បីចង់ដឹងថា មាននរណានៅខាងក្រោយ យើងពុំចាំបាច់ងាកក្បាលទៅក្រោយនោះទេ ដោយយើងគ្រាន់តែមើលទៅក្នុងកញ្ចក់ គឺយើងអាចមើលឃើញរូបភាពនៅខាងក្រោយយ៉ាងច្បាស់តែម្តង ដូច្នេះម៉ូតូនេះគឺដាក់កញ្ចក់ដើម្បីការមើលខាងក្រោយ។ យើងឃើញថាបុរសដែលជាប្តីនោះ គាត់គឺជាអ្នកឌុប អញ្ចឹងអ្នកដែលជិះម៉ូតូនៅខាងមុខ ហើយកាន់ចង្កូតម៉ូតូ គេហៅថាអ្នកឌុប បាទ បុរសនោះគាត់ពាក់អាវដៃខ្លីពណ៌ស្វាយ ស្លៀកខោពណ៌សជើងវែង និងមានពាក់ស្បែកជើងពណ៌ស អញ្ចឹងអម្បាញ់មិញយើងឃើញថាគាត់បានដោះស្បែកជើងចេញនៅពេលដែលគាត់ចូលក្នុងវត្ត ក៏ប៉ុន្តែនៅពេលដែលគាត់ចេញខាងក្រៅមកវិញ គឺគាត់ពាក់ស្បែកជើងវិញបាន ដូច្នេះគាត់ពាក់ស្បែកជើងប៉ាតាពណ៌ស ចំណែកនៅកណ្តាល គឺជាក្មេងប្រុសម្នាក់ អញ្ចឹងដោយសារតែកូនប្រុសរបស់គាត់នោះនៅតូច ដូច្នេះគាត់មិនអាចឲ្យកូនប្រុសរបស់គាត់ឌុប ឬក៏ជិះខាងក្រោយនោះទេ អញ្ចឹងគាត់បានឲ្យកូនប្រុសរបស់គាត់ជិះនៅកណ្តាល

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយកូនប្រុសរបស់គាត់ពាក់អាវដៃខ្លីពណ៌លឿង និងស្លៀកខោពណ៌ស
ហើយពាក់ស្បែកជើងផ្ទាត់។ នៅខាងក្រោយគឺជានារីម្នាក់ដែលជាម្ដាយ អញ្ចឹងនារីម្នាក់នោះ
គាត់ជិះខាងក្រោយក្មេងប្រុសម្នាក់នោះ ដើម្បីទប់ក្មេងប្រុសម្នាក់នោះ
ខ្លាចក្រែងលោក្មេងប្រុសម្នាក់នោះធ្លាក់ពីលើម៉ូតូ ព្រោះថាកូនក្មេង នៅពេលដែលគាត់ជិះ
គឺគាត់នៅមិនស្ងៀមនោះទេ គាត់អាចរើ ឬក៏គាត់អាចលេង ដូច្នេះអាចធ្វើឲ្យគាត់មានគ្រោះថ្នាក់បាន
នៅពេលដែលគាត់ប្រលែងគ្នា ឬក៏គាត់លេងច្រើន គាត់អាចធ្លាក់ពីលើម៉ូតូ
ឬក៏គាត់អាចធ្វើឲ្យម៉ូតូដួលបាន អញ្ចឹងហើយនារីម្នាក់នោះ
គាត់ត្រូវតែអង្គុយទប់ក្មេងប្រុសនោះឲ្យជាប់។ នារីម្នាក់នោះ គាត់អង្គុយពាក់ឆៀង។
អញ្ចឹងសម្រាប់នារី នៅពេលដែលគាត់ស្លៀកសំពត់ គាត់មិនអាចអង្គុយច្រកគាវបានទេ
អញ្ចឹងគាត់ពិបាកនឹងអង្គុយច្រកគាវណាស់ ដោយសារសំពត់របស់គាត់នឹងទើសជើងរបស់គាត់
ដូច្នេះគាត់ត្រូវអង្គុយច្រកគាវ គាត់ត្រូវអង្គុយពាក់ឆៀង។ អញ្ចឹងអង្គុយពាក់ឆៀង
គឺជាការអង្គុយបែរមកចំហៀង ដោយដាក់ជើងទាំងពីរសណ្ដូកទៅទិសតែមួយ
ហើយគាត់អង្គុយបែរចំហៀងលើម៉ូតូ គឺគាត់មិនអង្គុយច្រកគាវនោះទេ។

រូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញថា អ្នកទាំងបីនាក់បានជិះម៉ូតូមកដល់ផ្ទះ។
អញ្ចឹងគាត់បានត្រលប់មកពីវត្តវិញ នៅពេលដែល ក្រោយពេលដែលគាត់បានធ្វើបុណ្យរួចរាល់ហើយ
ប្រគេនចង្ហាន់ដល់ព្រះសង្ឃរួចរាល់ហើយ គាត់ក៏បានត្រលប់មកផ្ទះវិញ
ហើយគាត់បានត្រលប់មកផ្ទះដោយការជិះម៉ូតូ។ អញ្ចឹងគាត់ជិះម៉ូតូដល់ផ្ទះរបស់គាត់។
យើងឃើញថាផ្ទះរបស់គាត់គឺជាផ្ទះរបៀបអ្នកនៅស្រុកស្រែ បាទ ផ្ទះដែលនៅស្រុកស្រែ ព្រោះថា
ផ្ទះដែលនៅទីក្រុងគឺជាផ្ទះថ្ម ភាគច្រើនជាផ្ទះថ្ម ហើយសង់ជាប់នឹងដី ទាបជាប់នឹងដី ឬក៏មានពីរជាន់
ឬក៏បីជាន់ ឬក៏ជាផ្ទះល្វែង។
អញ្ចឹងផ្ទះដែលនៅទីក្រុងគឺមានលក្ខណៈទំនើបនិងស្រស់ស្អាតជាងផ្ទះដែលនៅស្រុកស្រែ។
ចំណែកឯនៅ ផ្ទះនៅក្នុងរូបភាពទី ៧ នេះ យើងឃើញថាគឺជាផ្ទះឈើមួយ បាទ ផ្ទះឈើ
ដែលខ្ពស់ផុតពីដី មានតែមួយជាន់នោះទេ ក៏ប៉ុន្តែគេហៅថាផ្ទះមានពីរខ្នង។ បាទ
ដោយសារតែមានដំបូលពីរជាប់គ្នា អញ្ចឹងផ្ទះខ្មែរ គេហៅថាផ្ទះពីរខ្នង ដែលផ្ទះនោះគឺខ្ពស់
ដោយមានសសរជាច្រើននៅខាងក្រោមផ្ទះ ដើម្បីទ្រផ្ទះឲ្យបានខ្ពស់ បាទ
អញ្ចឹងគេឡើងលើផ្ទះដោយកាំជណ្ដើរ អញ្ចឹងយើងឃើញថា មានកាំជណ្ដើរមួយសម្រាប់ឡើងលើផ្ទះ
ហើយកាំជណ្ដើរនោះមិនមានបង្កាន់ដៃនោះទេ។ អញ្ចឹងពេលខ្លះ ផ្ទះខ្លះ គាត់ដាក់ជណ្ដើរ
ហើយគាត់ដាក់បង្កាន់ដៃ។ បង្កាន់ដៃគឺដាក់នៅលើជណ្ដើរ
ដើម្បីឲ្យនៅពេលដែលយើងឡើងយើងអាចតោងបង្កាន់ដៃឡើង។
អញ្ចឹងវាអាចការពារសុវត្ថិភាពយើងកុំឲ្យធ្លាក់។ ប៉ុន្តែនៅក្នុងរូបភាពនេះ គឺជណ្ដើរនោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

មិនមានបង្កាន់ដៃសម្រាប់តោងឡើងនោះទេ។ ផ្ទះរបស់គាត់គឺមានទ្វារមួយ បាទ
ទ្វារនោះលើខាងមុខជណ្ដើរតែម្ដង អញ្ចឹងនៅពេលដែលយើងឡើងផុតជណ្ដើរ
គឺយើងឡើងដល់ទ្វារតែម្ដង។ ហើយនៅខាងមុខនោះ គឺគេហៅថារានហាល។ អញ្ចឹងរានហាល
គឺជាទីធ្លានៅខាងមុខផ្ទះនៅខាងលើ សម្រាប់ឲ្យយើងអង្គុយលេងជុំគ្នានៅខាងមុខផ្ទះបាន
ដោយយើងពុំចាំបាច់ចុះមកខាងក្រោមនោះទេ។ នៅខាងមុខរានហាលនោះ គឺយើងមានបង្កាន់ដៃ
អញ្ចឹងបង្កាន់ដៃ ឬក៏រនាំង ដែលធ្វើដើម្បីការពារខ្លាចក្មេងធ្លាក់ អញ្ចឹងគេធ្វើរនាំង
ឬក៏បង្កាន់ដៃនៅរានហាល ព្រោះថារានហាលគឺនៅខ្ពស់ ដូច្នេះគេធ្វើបង្កាន់ដៃដើម្បីបាំង
កុំឲ្យមានគ្រោះថ្នាក់ផ្សេងៗកើតឡើង។ អញ្ចឹងផ្ទះខ្មែរ គឺ ភាគច្រើនគេធ្វើផ្ទះខ្ពស់ឡើងផុតពីដី
ហើយផ្ទះនីមួយៗគឺត្រូវឡើងបាន ឡើងបានដោយកាំជណ្ដើរ
និងផ្ទះភាគច្រើនគឺមានរានហាលមួយនៅខាងមុខផ្ទះផងដែរ។

ចូលដល់រូបភាពទី ៨ នៅក្នុងរូបភាពទី ៨ គឺជារូបភាពមួយដែលអ្នក ក្នុងពិធីចូលឆ្នាំខ្មែរ
ប្រជាជនខ្មែរតែងតែធ្វើទាំងអស់គ្នា គឺជាការ ពិធីស្រង់ព្រះ អញ្ចឹងពិធីស្រង់ព្រះ គឺ កូនៗ ឬក៏ចៅៗ
ត្រូវយកទឹកទៅស្រោច ឬក៏ទៅងូតឲ្យមនុស្សចាស់នៅក្នុងផ្ទះ ដូចជាជីដូនជីតា
ឬក៏ឪពុកម្ដាយជាដើម។ អញ្ចឹងពាក្យថាស្រង់ព្រះនៅទីនេះ គឺបានន័យថាងូតទឹកឲ្យមនុស្សចាស់
ឬក៏ងូតទឹកឲ្យអ្នកមានគុណ។ អ្នកមានគុណ គឺយើងសំដៅទៅលើឪពុកម្ដាយ ឬក៏ជីដូនជីតា។
ជាក់ស្ដែងនៅក្នុងរូបភាពទី ៨ យើងឃើញថាមានមនុស្សចាស់ពីរនាក់ កំពុងតែអង្គុយនៅលើកៅអី
អញ្ចឹងមនុស្សចាស់ពីរនាក់នោះគឺជាយាយនិងតា ឬក៏យើងអាចហៅថា ជីដូនឬក៏ជីតា
អញ្ចឹងជីដូនគឺជាយាយ ជីតាគឺជាតា។ យើងឃើញជីដូននិងជីតាកំពុងតែអង្គុយនៅលើកៅអី
ហើយក្មេងប្រុសម្នាក់ គាត់លុតជង្គង់ ដោយចាក់ទឹកទៅលើដៃរបស់ជីតារបស់គេ
អញ្ចឹងគេធ្វើបែបនេះ គឺយើងហៅថាស្រង់ព្រះ បានន័យថាយើងលាងជម្រះខ្លួនប្រាណ
លាងជម្រះដៃជើង ទៅឲ្យអ្នកមានគុណ ឬក៏ឲ្យជីដូនជីតារបស់យើង។ អញ្ចឹងនៅក្នុងប្រទេសកម្ពុជា
គឺរាល់ពេលចូលឆ្នាំ គឺយើងតែងតែធ្វើពិធីស្រង់ព្រះ ដើម្បីរំលឹកគុណ
ឬក៏ដើម្បីធ្វើនូវសេចក្ដីដឹងគុណទៅដល់អ្នកដែលមានគុណរបស់យើង នៅក្នុងរូបភាពនេះ
គឺក្មេងប្រុស គាត់កំពុងតែស្រង់ព្រះទៅដល់ជីដូនជីតារបស់គាត់ ហើយឪពុកម្ដាយរបស់គាត់
ឪពុកម្ដាយរបស់ក្មេងប្រុសនោះ កំពុងតែឈរមើលនៅខាងក្រោយ។ អញ្ចឹងការស្រង់ព្រះ
គឺយើងធ្វើការស្រង់ម្ដងម្នាក់ ដោយដំបូងឡើយ គឺឲ្យឪពុកម្ដាយរបស់យើងស្រង់ ស្រង់ទឹក
ឬក៏យកទឹកទៅលាងជម្រះជីដូនជីតារបស់យើង ឬក៏ឪពុកម្ដាយរបស់គាត់ អញ្ចឹងបន្ទាប់មក
គឺយើងយកទឹកទៅលាងជម្រះកាយទៅដល់ឪពុកម្ដាយរបស់យើងវិញម្ដង។
ដូច្នេះគឺយើងស្រង់ព្រះម្ដងម្នាក់ ហើយតាមឋានានុក្រម អញ្ចឹងអ្នកណាចាស់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺយើងត្រូវឲ្យគាត់ស្រង់ព្រះមុន ឬក៏ឲ្យគាត់លាងជម្រះកាយមុន បន្ទាប់មកអ្នក
អ្នកណាក្មេងគឺត្រូវលាងជម្រះកាយបន្តបន្ទាប់គ្នា។

នៅក្នុងរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ បន្ទាប់ពីការធ្វើពិធីស្រង់ព្រះហើយ បាទ ពិធីស្រង់ព្រះ
បន្ទាប់ពីធ្វើហើយ គឺឪពុកម្ដាយ ឬក៏ជីដូនជីតា គាត់តែងតែឲ្យពរទៅដល់កូនចៅឲ្យបានសុខសប្បាយ
និងមានសេចក្ដីសុខ។ បន្ទាប់មក បន្ទាប់ពីការធ្វើពិធីស្រង់ព្រះហើយ
គ្រួសារខ្មែរតែងតែអង្គុយញ៉ាំបាយជុំគ្នា។ អញ្ចឹងនៅក្នុងរូបភាពទី ៩ នេះ គឺយើងឃើញថា
គ្រួសារនោះ គាត់កំពុងតែអង្គុយញ៉ាំបាយជុំគ្នា ដោយទម្លាប់នៅក្នុងគ្រួសារខ្មែរ
ឬក៏នៅក្នុងប្រទេសកម្ពុជា ការញ៉ាំអាហារជុំគ្នាពេលល្ងាច ឬក៏ពេលថ្ងៃត្រង់
គឺយើងពុំប្រើប្រាស់តុនោះទេ គឺយើងក្រាលកន្ទេល អញ្ចឹងយើងញ៉ាំបាយនៅលើកន្ទេល
ឬក៏កម្រាលមួយ ព្រោះថាជាទម្លាប់តាំងពីដើម គឺយើងប្រើប្រាស់កន្ទេលបែបនេះតែម្ដង។
អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញថាគ្រួសារនោះ គាត់បានក្រាលកន្ទេលមួយ
ដោយមានម្ហូបនៅលើកន្ទេលនោះជាច្រើន មានដូចជា យើងឃើញដូចជាត្រី និងបន្លែ
ត្រីគឺយើងដាក់នៅក្នុងចានរាបឬក៏ចានពងក្រពើមួយ បន្លែគឺដាក់នៅក្នុងចានទាបតូចៗ ចំនួនពីរ
ហើយយើងឃើញមានទឹកសម្លដែលដាក់នៅក្នុងចានគោម
អញ្ចឹងម្ហូបទាំងអស់គឺយើងដាក់នៅកណ្ដាល ពួកគាត់បានដាក់ម្ហូបទាំងអស់នៅកណ្ដាល
ហើយមនុស្ស[ដែល]នៅក្នុងគ្រួសារនោះ គាត់បានអង្គុយជុំវិញម្ហូបនោះដើម្បីញ៉ាំបាយជាមួយនឹងម្ហូប
យើងឃើញថា មនុស្ស[នីមួយៗ] គ្រួសារនីមួយៗ សមាជិកនីមួយៗ គាត់បានកាន់ចានបាយឡើង
ហើយគាត់ក៏បានចាប់ចង្កឹះឬក៏ស្លាបព្រា ដើម្បីដួសបាយញ៉ាំជាមួយនឹងម្ហូប
អញ្ចឹងជាទូទៅនៅក្នុងប្រទេសកម្ពុជា ដើម្បីរក្សាសុជីវធម៌ និងគេហៅថា ដើម្បីរក្សាសីលធម៌
ការញ៉ាំបាយ គឺត្រូវឲ្យមនុស្សចាស់គាត់លូកមុន។ អញ្ចឹងម្ហូប ទោះបីជាយើងឃ្លានយ៉ាងណាក៏ដោយ
ប្រសិនបើយើងញ៉ាំជាមួយមនុស្សចាស់ យើងមិនត្រូវញ៉ាំមុនមនុស្សចាស់នោះទេ
គឺត្រូវឲ្យមនុស្សចាស់ គាត់លូកម្ហូបមុន ឬក៏គាត់ដួសម្ហូបយកមកពិសាមុន
ទើបយើងអាចញ៉ាំបានតាមក្រោយ ធ្វើដូច្នេះ គឺសម្ដែងនូវការគោរពដល់គាត់
អញ្ចឹងយើងគោរពមនុស្សចាស់ ដូច្នេះយើងត្រូវតែពិសាអាហារឬក៏ញ៉ាំអាហារក្រោយគាត់។
អញ្ចឹងត្រូវឲ្យមនុស្សចាស់ពិសាអាហារមុន។ នៅពេលដែលក្មេងគេហៅថាញ៉ាំ ចំណែក[...]
និយាយជាមួយមនុស្សចាស់យើងហៅថាពិសាឬក៏ហូប។
ហូបគឺប្រើចំពោះមនុស្សដែលអាយុបងយើងតិចៗ ឬក៏បងយើងបន្តិច ចំណែកឯពិសា
គឺយើងប្រើជាមួយមនុស្សចាស់ ជាមួយឪពុកម្ដាយឬក៏ជីដូនជីតា អញ្ចឹងគឺយើងហៅពិសា
គឺវាគួរសមជាងហូប។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មករូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញថា មានក្មេងៗចំនួន ៣ នាក់ បាទ គាត់កំពុងតែរត់លេងទឹក បាទ អញ្ចឹងនៅពេលដែលក្នុងថ្ងៃចូលឆ្នាំ គឺ យើងមានពិធីច្រើន ដូចជាស្រង់ព្រះ ដូចជាការលេងល្បែងប្រជាប្រិយ ហើយស្រង់ព្រះគឺយើងលេងជាមួយនឹងទឹក ដូច្នេះ បន្ទាប់ពីយើងស្រង់ព្រះឲ្យអ្នកមានគុណ ឬក៏ឲ្យចាស់ៗរួចរាល់ហើយ យើងក៏បានយកទឹកមកជះដាក់គ្នាលេង អញ្ចឹងយើងលេងទឹកដោយជះដាក់គ្នាទៅវិញទៅមក ហើយការលេងបែបនេះ គឺយើងមិនប្រកាន់គ្នានោះទេ ព្រោះថាជាថ្ងៃចូលឆ្នាំថ្មី គឺយើងសប្បាយ យើងលាងជម្រះខ្លួនឲ្យគ្នាទៅវិញទៅមក ដើម្បីឲ្យជ្រះនូវភាពចង្រៃ ឬក៏រឿងរ៉ាវអាក្រក់ៗទាំងប៉ុន្មានឲ្យទៅតាមទឹកទាំងអស់។ ដូចនៅក្នុងរូបភាពនេះ យើងឃើញថា មានក្មេងស្រីម្នាក់ បាទ ក្មេងស្រីនោះ គាត់ពាក់អាវដៃខ្លីពណ៌ទឹកក្រូច ស្លៀកខោជើងខ្លីពណ៌ស ក្មេងស្រីនោះអាយុប្រហែលជា ១៥ ឆ្នាំ ឬក៏ ១០ ឆ្នាំ គាត់ចងសក់ទីទុយ បាទ គាត់ចងសក់ទីទុយ ដោយដៃទាំងពីររបស់គាត់កាន់ធុងទឹកពណ៌បៃតងមួយ អញ្ចឹងគាត់កាន់ធុងទឹក ហើយគាត់រត់មកជះទឹកដែលនៅក្នុងធុងនោះ ទៅដាក់ក្មេងប្រុសម្នាក់ បាទ យើងឃើញក្មេងប្រុសម្នាក់នោះ គឺគាត់ដោះអាវ គាត់មិនមានពាក់អាវនោះទេ ហើយគាត់ស្លៀកខោជើងខ្លីពណ៌ស ដោយដៃរបស់គាត់កាន់កាំភ្លើងបាញ់ទឹក អញ្ចឹងគាត់កាន់កាំភ្លើងបាញ់ទឹក ដោយលើកកាំភ្លើងនោះឡើងលើ ហើយដៃគាត់ទាំងពីរគឺលើកឡើងលើ ដោយដៃម្ខាងគាត់យកទៅបាំងមុខរបស់គាត់ ដោយគាត់មិនចង់ឲ្យទឹកមកទទឹកមុខរបស់គាត់។ អញ្ចឹងនៅពេលដែលគាត់លេងជះទឹក គឺគាត់នឹងសើមខ្លួនទាំងអស់ ដូច្នេះពេលខ្លះគាត់គ្រាន់តែយកដៃមកបាំងមុខ ដើម្បីកុំឲ្យទឹកចូលភ្នែកគាត់តែប៉ុណ្ណោះ។ នៅខាងក្រោយក្មេងប្រុសម្នាក់នោះ យើងឃើញមានក្មេងប្រុសម្នាក់ទៀត កំពុងតែរត់មកលេងជាមួយគ្នាដែរ ដែលក្មេងប្រុសម្នាក់នោះ គាត់ពាក់អាវពណ៌លឿង ដៃខ្លី ស្លៀកខោជើងខ្លីពណ៌លឿង ហើយក្មេងប្រុសម្នាក់នោះ គាត់ក៏កំពុងតែកាន់កាំភ្លើងបាញ់ទឹកមួយផងដែរ។ គាត់កាន់កាំភ្លើងបាញ់ទឹក គឺដើម្បីបាញ់ទឹកលេងជាមួយនឹងក្មេងៗដទៃទៀតដែលនៅក្នុងភូមិ បាទ ពួកគេទាំងអស់គ្នារត់លេងយ៉ាងសប្បាយរីករាយ ដោយយើងឃើញទឹកមុខរបស់ពួកគេគឺញញឹម និងសប្បាយដោយការលេងទឹកនៅក្នុងថ្ងៃចូលឆ្នាំថ្មីនេះតែម្ដង។ ហើយនៅក្បែរនោះ យើងឃើញថា មានសត្វឆ្កែមួយកំពុងតែរត់នៅក្បែរក្មេងស្រី អញ្ចឹងថ្ងៃចូលឆ្នាំមិនត្រឹមតែសប្បាយតែមនុស្សទេ សូម្បីតែសត្វក៏សប្បាយដែរ ព្រោះយើងទាំងអស់គ្នាគឺលេងសប្បាយជាមួយនឹងគ្នា ជាមួយនឹងទឹកនោះតែម្ដង។

ចូលដល់រូបភាពទី ១១ រូបភាពទី ១១ នៅក្នុងពិធីចូលឆ្នាំខ្មែរ ពេលខ្លះគឺយើងលេងទឹក ហើយនៅក្នុងតំបន់ខ្លះ គាត់លេងប៉ាតម្សៅគ្នា។ អញ្ចឹងគាត់យកម្សៅដែលក្រអូបៗ បាទ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់យកមកដាក់នៅនឹងដៃរបស់គាត់ បន្ទាប់មកគឺគាត់យកទៅជូតនឹងមុខអ្នកដទៃ។ ដូចជាក់ស្តែង យើងឃើញនៅក្នុងរូបភាពទី ១១ នេះ គឺមានក្មេងប្រុសម្នាក់ បាទ គាត់យកម្សៅ ដែលដៃម្ខាងគាត់មានម្សៅមួយពំនូក ហើយគាត់បានយកដៃម្ខាងទៀតទៅទះថ្ពាល់របស់ក្មេងស្រីនោះ ដោយគាត់យកម្សៅទៅលាបលើមុខរបស់ក្មេងស្រី អញ្ចឹងយើងលាបមុខឲ្យគ្នាទៅវិញទៅមក ដើម្បីឲ្យសប្បាយរីករាយ ហើយបានន័យថា យើងបានលាបរបស់ល្អៗ ឬក៏លាបសុភមង្គល ឬក៏សេចក្តីសប្បាយរីករាយទៅលើអ្នកដទៃ អញ្ចឹងយើងចែករំលែកសេចក្តីសប្បាយរីករាយ ទៅឲ្យគ្នាទៅវិញទៅមកតាមរយៈការលាបម្សៅនេះផងដែរ។

នៅក្នុងរូបភាពទី ១២ នៅក្នុងរូបភាពទី ១២ យើងឃើញថា មានមនុស្សចំនួនពីរក្រុម ដែលក្នុងនោះមានប្រុសមួយក្រុម និងស្រីមួយក្រុម គាត់កំពុងតែលេងចោលឈូង អញ្ចឹងចោលឈូងគឺជាល្បែងប្រជាប្រិយរបស់ខ្មែរ ដែលគេតែងតែលេងនៅក្នុងពិធីចូលឆ្នាំថ្មី ដែលល្បែងនេះ គឺយើងលេងដោយចែកចេញជាពីរក្រុម គឺស្រីមួយក្រុមនិងប្រុសមួយក្រុម ដែល ហើយឈូង គឺគេធ្វើអំពីបាល់។ ឈូងគឺជាបាល់ក្រណាត់ បាទ ជាបាល់មួយដែលធ្វើអំពីក្រណាត់ ដែលក្រណាត់នោះ គឺយើងចងចេញជាបាល់ ហើយមានកន្ទុយមួយ យើងទុកកន្ទុយមួយសម្រាប់ចោល។ អញ្ចឹងខាងប្រុស នៅពេលនោះ គឺយើងឲ្យម្ខាងចោលបាល់ឈូងនោះ ហើយម្ខាងទៀតជាអ្នកចាប់ឈូង អញ្ចឹងនៅពេលដែលយើងចោល អ្នកខាងចាប់ត្រូវតែចាប់ឲ្យបាន បន្ទាប់ពីចាប់ហើយ យើងត្រូវគប់មករកអ្នកដែលចោលវិញ។ ប៉ុន្តែឈូងនោះ គឺមិន គប់និងចោលមិនមានគ្រោះថ្នាក់នោះទេ ព្រោះថាបាល់ដែលធ្វើពីក្រណាត់ ទោះជាប៉ះទង្គិច ក៏មិនមានការឈឺចាប់ ឬក៏មិនមានគ្រោះថ្នាក់ដែរ គឺគេលេងដើម្បីសប្បាយរីករាយ អញ្ចឹងហើយទើបគេធ្វើបាល់នោះអំពីក្រណាត់ ដូច្នេះវាមិនបង្កឲ្យមានផលប៉ះពាល់ ឬក៏មិនបង្កឲ្យមានរបួសនោះទេ។ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថា មានមនុស្សប្រុសមួយក្រុម បាទ គាត់កំពុងតែបោះឈូងទៅឲ្យខាងស្រី ចំណែកឯខាងស្រីមួយក្រុមនោះ គាត់កំពុងតែយកដៃ ដើម្បីចាប់ឈូង ដែលខាងប្រុសនោះគាត់បោះទៅ។ អញ្ចឹងការចោលឈូង គឺយើងមានលក្ខខណ្ឌគ្នា បាទ គឺប្រសិនបើយើងចោលឈូងទៅម្ខាងទៀតចាប់មិនបានទេ គឺម្ខាងនោះត្រូវតែច្រៀង ឬក៏រាំទៅតាមការចង់បានរបស់អ្នកចោលឈូង ឬក៏របស់អ្នកដែលឈ្នះ អញ្ចឹងនៅពេលដែលយើងចាប់ឈូងអត់បាន គឺយើងក្លាយដូចជាអ្នកចាញ់។

បន្ទាប់មករូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ យើងឃើញថា បន្ទាប់ពីលេងចោលឈូងហើយ យើងឃើញនៅពេលនោះ ខាងស្រីគឺចាញ់ ដោយគាត់មិនចាប់ឈូងមិនបាននោះទេ អញ្ចឹងហើយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ខាងប្រុស គាត់តម្រូវឲ្យខាងស្រីគាត់រាំ។ អញ្ចឹងការលេងចោលឈូង
គឺយើងមិនមែនជាល្បែងស៊ីសងនោះទេ គឺជាល្បែងប្រជាប្រិយ
ដែលខ្មែរយើងតែងតែលេងនៅក្នុងពិធីចូលឆ្នាំ ដូច្នេះការចាញ់ឈ្នះមិនមានការភ្នាល់ដាក់លុយ
ឬក៏ដាក់ទ្រព្យសម្បត្តិផ្សេងៗនោះទេ ព្រោះថាល្បែងភ្នាល់ដាក់លុយ ឬក៏ដាក់ទ្រព្យសម្បត្តិ
គឺជាអំពើខុសច្បាប់។ ដូច្នេះគឺយើងលេងនៅត្រឹមតែជាការឲ្យច្រៀង ឬក៏ឲ្យរាំ។
ដូចនៅក្នុងរូបភាពនេះ នៅពេលដែលខាងស្រីគាត់ចាញ់ គាត់បាន ខាងប្រុសគាត់បានឲ្យខាងស្រីរាំ
អញ្ចឹងខាងស្រី គាត់ក៏បានរាំ ហើយខាងប្រុសក៏បានច្រៀងនិងទះដៃ
អញ្ចឹងយើងលេងល្បែងនេះគឺសប្បាយរីករាយទាំងអស់គ្នា មិនថាប្រុស មិនថាស្រី មិនថាក្មេង
មិនថាចាស់ គឺអាចលេងបានទាំងអស់។ អញ្ចឹងហើយយើងឃើញថា នៅក្នុងរូបភាពនេះ
គឺមានខាងស្រីកំពុងតែលើកដៃរាំ ដោយពួកគាត់រាំចង្វាក់ប្រពៃណីខ្មែរ ហើយដោយឲ្យខាងប្រុស
គាត់ជាអ្នកច្រៀងចម្រៀង ដែលគាត់ចង់បាន។

ចូលដល់រូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ គឺជាល្បែងប្រជាប្រិយខ្មែរមួយមុខទៀត
គេហៅថាលេងចាប់កូនខ្លែង។ អញ្ចឹងលេងចាប់កូនខ្លែង គឺយើងត្រូវបែងចែកជាពីរក្រុម
ដោយមួយក្រុមមានមនុស្សច្រើនអ្នក ឈរតម្រង់ជួរគ្នាដោយឱបចង្កេះគ្នាទៅវិញទៅមក។
អញ្ចឹងមួយក្រុមគឺឈរតម្រង់ជួរគ្នាដោយតោងចង្កេះគ្នាពីមុខទៅក្រោយ បាទ
ហើយម្នាក់មួយក្រុមទៀតគឺមានសមាជិកតែម្នាក់ប៉ុណ្ណោះ ដោយគាត់ដើរតួជាខ្លែង
ចំណែកឯមនុស្សមួយក្រុមដែលឈរតម្រង់ជួរគ្នាដើរតួជាមាន់
ហើយនៅខាងមុខគេគឺជាដើរតួជាមេមាន់ អញ្ចឹងខ្លែងត្រូវទៅសុំចាប់កូនមាន់ពីមេមាន់
ប៉ុន្តែនៅពេលដែលខ្លែងទៅ ខ្លែងត្រូវច្រៀងសុំចាប់កូនខ្លែងពីមេមាន់ ហើយមេមាន់មិនព្រមនោះទេ
ដោយមេមាន់ព្យាយាមការពារកូនមាន់នោះឲ្យខានតែងបាន។
អញ្ចឹងល្បែងនេះគឺយើងយកតម្រាប់ទៅតាមសត្វខ្លែង
ហើយនិងសត្វមាន់ដែលជាសត្វរស់នៅនៅក្នុងស្រុកភូមិ
ហើយសត្វខ្លែងតែងតែមកឆាបកូនមាន់យកទៅស៊ី ហើយមេមាន់តែងតែការពារកូនមាន់របស់គេ
ដូច្នេះខ្មែរយើងក៏បានមើលសកម្មភាពរបស់សត្វទាំងពីរ ហើយក៏បង្កើតជាល្បែងនេះឡើង។
អញ្ចឹងនៅពេលនោះ ខ្លែងត្រូវតែព្យាយាម ធ្វើយ៉ាងណា ចាប់មនុស្សដែលនៅខាងក្រោយឲ្យបាន
ហើយមេមាន់ព្យាយាមរត់ទៅបាំងខ្លែងដើម្បីកុំឲ្យចាប់កូនមាន់បាន។
អញ្ចឹងកូនមាន់ដែលនៅខាងក្រោយ ឬក៏មនុស្សដែលនៅខាងក្រោយ ត្រូវតែព្យាយាមរត់តាមមេមាន់
ដើម្បីកុំឲ្យខ្លែងចាប់បាន នៅពេលដែលខ្លែងចាប់បាននោះ
កូនមាន់នោះនឹងក្លាយទៅជាចំណីរបស់ខ្លែង ហើយគេនឹងក្លាយទៅជាអ្នកចាញ់
បន្ទាប់មកអ្នកចាញ់នឹងត្រូវច្រៀង ឬក៏រាំទៅតាមអ្វីដែលអ្នកឈ្នះចង់បាន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងល្បែងប្រជាប្រិយខ្មែរដែលលេងនៅក្នុងពិធីចូលឆ្នាំខ្មែរគឺមានច្រើនប្រភេទ
មានដូចជាចោលឈូង បោះអង្គញ់ ចាប់កូនខ្លែង លាក់កន្សែងជាដើម។ ហើយល្បែងទាំងអស់នោះ
ពុំមែនជាល្បែងស៊ីសងនោះទេ វាគឺជាល្បែងប្រពៃណី ឬក៏ល្បែងប្រជាប្រិយ
ដែលប្រជាជនខ្មែរតែងតែលេងដើម្បីភាពសប្បាយរីករាយនៅក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី។
ហើយពិធីបុណ្យចូលឆ្នាំថ្មីរបស់ប្រទេសកម្ពុជា តែងតែធ្វើឡើងនៅក្នុងខែមេសា បាទ
ខែមេសាដែលជាខែប្រាំង ហើយយើងធ្វើឡើងនេះគឺនៅក្នុង ពេលដែលប្រមូលផលរួច
អញ្ចឹងនៅពេលដែលប្រជាជនគាត់ប្រមូលផលស្រែចំការគាត់រួចរាល់ហើយ
គាត់ក៏បានរៀបចំពិធីចូលឆ្នាំថ្មីនេះ ដើម្បីជួបជុំគ្នាសប្បាយរីករាយ និងដើម្បីអបអរនូវផលដំណាំ
ដែលគាត់បានប្រមូលរួចរាល់ ដូច្នេះគឺយើងតែងតែប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីនៅក្នុងខែមេសា
ដែលជាខែដែលប្រជាជនខ្មែរទាំងអស់ទូទាំងប្រទេស គាត់បានប្រមូលផលដំណាំគ្នារួចរាល់
បន្ទាប់មកប្រជាជនខ្មែរ គាត់ក៏បានជួបជុំគ្នា ដើម្បីលេងល្បែងប្រជាប្រិយ
ក្នុងការកម្សាន្តនៅក្នុងភូមិរបស់គាត់ផងដែរ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.